Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ធ្វើ សេចក្តីសម្រេចចិត្តប្រកបដោយ សុវត្ថិភាព ក្នុងអំឡុងរលកយក្សស៊ូណាមិ

## ដឹងអំពី ការព្រមាននានា



**ការិយាល័យឧតុនិយម** នឹងចេញ **ការឃ្លាំមើល, ការព្រមានសមុទ្រ** ឬ **ការព្រមានដីផ្អែក**លើហានិភ័យរលកយក្សស៊ូណាមិ។ ពួកគេនឹងចេញ **ការលុបចោលការឃ្លាំមើលរលកយក្សស៊ូណាមិ** ឬ **ការលុបចោលការព្រមានរលកយក្សស៊ូណាមិ** នៅពេលការគំរាមកំហែងសំខាន់បានកន្លងផុតទៅ ឬរលកយក្សស៊ូណាមិមិនបានកើតឡើងជាយថាហេតុទេ។

**NSW SES** នឹងចេញការព្រមានដូចខាងក្រោម អាស្រ័យលើកម្រិតនៃហានិភ័យរលកយក្សស៊ូណាមិ៖

### ដំបូន្មាន - បន្តទទួលបានព័ត៌មាន

បានចេញផ្សាយ នៅពេលដែលមានលទ្ធភាពនៃរលកយក្សស៊ូណាមិនឹងកើតឡើង។

### ដំបូន្មាន - លក្ខខណ្ឌត្រួតពិនិត្យ

ការព្រមាននេះបានចេញនៅពេលការគំរាមកំហែងពីរលកយក្សស៊ូណាមិបានកន្លងផុតទៅ។

### ដំបូន្មាន - ត្រឡប់ទៅវិញដោយប្រុងប្រយ័ត្នចំពោះការគំរាមគំហែងដែលបានកាត់បន្ថយ

ការព្រមាននេះបានចេញ នៅពេលវាមានសុវត្ថិភាព ដើម្បីត្រឡប់ទៅតំបន់ជម្លៀសវិញ។

### ការព្រមានក្នុងគ្រាអាសន្ន - ជៀសវាងតំបន់

បានចេញផ្សាយ នៅពេលដែលមានការគំរាមកំហែងនៃរលកយក្សស៊ូណាមិនៅតំបន់តាមសមុទ្រ និងមហាសមុទ្រ និងច្រាំងសមុទ្រអាចនឹងរងផលប៉ះពាល់។ ការព្រមាននេះណែនាំដល់សមាជិកនៃសាធារណជនកុំឲ្យប្រើប្រាស់តំបន់នៅតាមសមុទ្រ។

### ការព្រមានក្នុងគ្រាអាសន្ន - ជម្លៀស

បានចេញផ្សាយនៅពេលមានការគំរាមកំហែងនៃរលកយក្សស៊ូណាមិដល់តំបន់ដីឆ្នេរសមុទ្រ។ ការព្រមាននេះណែនាំដល់សមាជិកនៃសាធារណជនឲ្យជម្លៀសចេញពីតំបន់ជម្លៀស។




ក្នុងស្ថានភាពគំរាមកំហែងដល់អាយុជីវិត ហៅទូរសព្ទទៅ **លេខសូន្យបីដង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES

Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ធ្វើ សេចក្ដីសម្រេចចិត្តប្រកបដោយ សុវត្ថិភាព ក្នុងអំឡុងរលកយក្សស៊ូណាមិ

## ចាត់វិធានការប្រកបដោយសុវត្ថិភាព

វាអាចមានពេលវេលាតិចតួចដើម្បីត្រៀមខ្លួន – អ្នកត្រូវធ្វើសកម្មភាពឱ្យបានភ្លាមៗ។

ធ្វើតាមការណែនាំទាំងអស់ដែលបានផ្ដល់នៅក្នុងការព្រមានអំពីរលកយក្សស៊ូណាមិ៖




**ការព្រមានគ្រោះអាសន្ន - ជៀសវាងតំបន់**– ចេញពីទឹក និងផ្លាស់ទីចេញឱ្យឆ្ងាយពីតំបន់តាមសមុទ្រ និងផ្លូវទឹកដែលតភ្ជាប់ទៅមហាសមុទ្រ។



**ការព្រមានក្នុងគ្រោះអាសន្ន - ជម្លៀស**– ផ្លាស់ទីចេញឱ្យឆ្ងាយយ៉ាងតិច 1 គីឡូម៉ែត្រផ្នែកព័ទ្ធដោយដី។ ប្រសិនបើអ្នកមិនអាចចាកចេញបានទេ សូមផ្លាស់ទីទៅអគាមាំមួយ យ៉ាងតិច 10 ម៉ែត្រ ខ្ពស់លើកម្រិតសមុទ្រធម្មតា។



ប្រសិនបើអ្នកស្ថិតនៅ ក្នុងទឹករាក់ ទឹកតាមឆ្នេរសមុទ្រ – ត្រឡប់ទៅមាត់ឆ្នេរវិញ ធានាសុវត្ថិភាពកប៉ាល់របស់អ្នក និងផ្លាស់ទីចេញឱ្យឆ្ងាយពីទឹក។



ប្រសិនបើអ្នកនៅ ក្រៅឆ្នេរ – សូមចេញទៅបន្ថែមទៀតទៅទឹកដែលកាន់តែជ្រៅ។

- ស្ដាប់ និងឃ្លាំមើលសញ្ញាធម្មជាតិនៃរលកយក្សស៊ូណាមិ។
- ស៊ីរ៉ែនពេលគ្រោះអាសន្នអាចឮសំឡេងនៅកន្លែងខ្លះប្រសិនបើមានការគំរាមកំហែងពីរលកយក្សស៊ូណាមិ។
- សារជាអក្សរ ឬសារសំឡេងថតអាចត្រូវបានផ្ញើទៅអ្នកទាំងនោះដែលស្ថិតនៅក្នុងតំបន់រងផលប៉ះពាល់។
- នៅពេលបានទទួលសារនេះ បន្ទាប់វាបានផ្ដល់ដំបូន្មានថាអ្នកត្រូវអនុវត្តតាមជំហាននានាដើម្បីសុវត្ថិភាព។
- កុំរង់ចាំសារនេះ ប្រសិនបើអ្នកបានឮវាតាមរយៈប្រភពដទៃទៀត។



ក្នុងស្ថានភាពគំរាមកំហែងដល់អាយុជីវិត ហៅទូរសព្ទទៅ **លេខសូន្យបីដង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES

Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ធ្វើ សេចក្ដីសម្រេចចិត្តប្រកបដោយសុវត្ថិភាព ក្នុងអំឡុងរលកយក្សស៊ូណាមិ

## អនុវត្តតាមផែនការជម្លៀសពីរលកយក្សស៊ូណាមិរបស់អ្នក

- ដើរទៅកាន់តំបន់ដែលមានសុវត្ថិភាពរបស់អ្នក ជៀសវាងការបើកបរ ពីព្រោះផ្លូវអាចរាំងស្ទះដោយចរាចរណ៍លើសលប់។
- ត្រូវប្រាកដថាអ្នកជិតខាង ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកដឹងអំពីការព្រមានបច្ចុប្បន្ន។
- យកកញ្ចប់សង្គ្រោះបន្ទាន់របស់អ្នកទៅជាមួយអ្នក។
- សូមស្តាប់វិទ្យុ និងទូរទស្សន៍នៅតាមតំបន់របស់អ្នក ដើម្បីទទួលបានការធ្វើបច្ចុប្បន្នភាពថ្មីៗ។

## ប្រសិនបើអ្នកត្រូវបានគេជម្លៀសចេញ

ការិយាល័យឧតុនិយមនឹងចេញ **ការលុបចោលការឃ្លាំមើលរលកយក្សស៊ូណាមិ** ឬ **ការលុបចោលការព្រមានអំពីរលកយក្សស៊ូណាមិ** នៅពេលការគំរាមកំហែងរលកយក្សស៊ូណាមិបានចប់។

NSW SES នឹងចេញ **ដំបូន្មាន៖ ត្រឡប់ទៅវិញដោយប្រុងប្រយ័ត្ន** នៅពេលវាមានសុវត្ថិភាពត្រឡប់ទៅតំបន់ដែលបានរងផលប៉ះពាល់។

កុំត្រឡប់ទៅកាន់តំបន់ដែលរងផលប៉ះពាល់រហូតដល់សេវាសង្គ្រោះបន្ទាន់ប្រកាសថាវាមានសុវត្ថិភាព។ វាអាចមិនមានសុវត្ថិភាពក្នុងការត្រឡប់ទៅវិញសម្រាប់រយៈពេលយូរ។







មជ្ឈមណ្ឌលស្តារឡើងវិញគ្រោះមហន្តរាយ និងមជ្ឈមណ្ឌលជម្លៀសអាចត្រូវបានបង្កើតឡើងបន្ទាប់ពីរលកយក្សស៊ូណាមិ។

ចាត់ចែងឱ្យមានកន្លែងសុវត្ថិភាពដែលត្រូវទៅ ដែលស្ថិតនៅក្រៅតំបន់រងផលប៉ះពាល់ដោយរលកយក្សស៊ូណាមិ ជាឧទាហរណ៍នៅផ្ទះមិត្តភក្តិ ឬសាច់ញាតិ។ ប្រសិនបើវាមិនមែនជាជម្រើសទេ សូមទៅកាន់មជ្ឈមណ្ឌលជម្លៀស។

នៅឱ្យឆ្ងាយពីតំបន់ដែលរងផលប៉ះពាល់ដោយរលកយក្សស៊ូណាមិ ហើយកុំទៅមើលទេសភាពនៅទីនោះ។

ក្នុងស្ថានភាពគំរាមកំហែងដល់អាយុជីវិត ហៅទូរសព្ទទៅ **លេខសូន្យបីដង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES

Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ធ្វើ សេចក្តីសម្រេចចិត្តប្រកបដោយ សុវត្ថិភាព ក្នុងអំឡុងរលកយក្សស៊ូណាមិ

## ប្រសិនបើអ្នកជាប់គាំង

ហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500** ប្រសិនបើអ្នកត្រូវការជំនួយក្នុងគ្រាអាសន្ន ឬ **លេខសូន្យបីដង (000)** ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពគំរាមកំហែងដល់ជីវិត។

ប្រសិនបើអ្នកស្ថិតនៅកន្លែងមានសុវត្ថិភាព ហើយមិនត្រូវការជំនួយសង្គ្រោះបន្ទាន់ភ្លាមៗទេ សូមស្នាក់នៅទីនោះ និងរង់ចាំជំនួយ។



## ប្រសិនបើអ្នកអាច

ជួយអ្នកដទៃដែលកំពុងត្រូវការជំនួយ ប្រសិនបើអ្នកអាចធ្វើបាន ហើយប្រសិនបើវាមានសុវត្ថិភាពប៉ុណ្ណោះ។

បន្តស្តាប់រកព័ត៌មាន ដំបូន្មាន និងបច្ចុប្បន្នភាពថ្មីៗ។



ក្នុងស្ថានភាព គំរាមកំហែងដល់អាយុជីវិត ហៅទូរសព្ទទៅ **លេខសូន្យបីដង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ 132 500។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES